# *THE FUTURE*

234. There are several ways of talking about the future in English: the Simple Future Tense, the *going to* form, the Simple Present Tense, etc.

234. នៅក្នុងភាសាអង់គ្លេសមានមធ្យោបាយជាច្រើនដែលនិយាយអំពីអនាគតកាល ដូចជា Simple Future Tense ដូចជាទំរង់ going to, ដូចជា Simple Present Tense ជាដើម ។ល។

## *Simple Future Tense*

235. The Simple Future Tense is used to talk about things which we cannot control. It expresses the future as fact.

235. អនាគតកាលធម្មតាត្រូវបានគេប្រើដើម្បីនិយាយអំពីអ្វីៗដែលយើងមិនអាចគ្រប់គ្រងបាន។ វាបញ្ជាក់ពីពេលអនាគតដែលជាការពិត។

I *shall be* twenty next Saturday.

ថ្ងៃសៅរ៍ក្រោយខ្ញុំអាយុ២០ឆ្នាំហើយ។

It *will be* Diwali in a week.

វានឹងទៅដល់ Diwali ក្នុងមួយសប្តាហ៍។

We *will know* our exam results in May.

យើងនឹងដឹងលទ្ធផលប្រលងនៅខែឧសភា។

236. We use this tense to talk about what we think or believe will happen in the future.

236. យើងប្រើកាលនេះដើម្បីនិយាយអំពីអ្វីដែលយើងគិតថាឬជឿថានឹងកើតឡើងនៅក្នុងពេលអនាគត។

(ការព្យាករណ៍ហេតុការណ៍ដែលនឹងកើតឡើងនៅក្នុងពេលអនាគត = Prediction)

I think Pakistan *will win* the match.

ខ្ញុំគិតថា Pakistan នឹងឈ្នះការប្រកួត។

I'm sure Helen *will get* a first class.

ខ្ញុំជឿថា Helen នឹងទទួលបានថ្នាក់លេខ១។

www.salarean.com

As in the above sentences, we often use this tense with *I think*, and *I'm sure*. We also say *I expect ____, I believe ______, Probably ______*, etc.

ដូចនៅក្នុងឃ្លាខាងលើអញ្ចឹងជាញឹកញាប់យើងប្រើកាលនេះជាមួយពាក្យ I think និងពាក្យ I'm sure។ យើងក៏ប្រើវាផងដែរជាមួយនឹង I expect____, I believe ____, Probably ____, ។ល។

| | |
|---|---|
| *I think*<br>*I hope*<br>*I'm sure*<br>*I promise*<br>*I exprect*<br>*I believe, tect* | + that.....will..... |

*May* be he will agree.
He will *probably* agree.
*Perhaps*, he will agree.
It is possible / probably / likely that he *will* agree.

= គាត់ប្រហែលជាយល់ព្រម។

He may agree.
He is likely to agree.

= គាត់ប្រហែលជាយល់ព្រម។

237. We can use this tense when we decide to do something at the time of speaking. (=immediately decision)

237. យើងប្រើកាលនេះនៅពេលដែលការសំរេចចិត្តធ្វើអ្វីមួយនៅពេលនិយាយតែម្តង។ (=ការសំរេចចិត្តភ្លាមៗ)

at the time of speaking = នៅពេលនិយាយ

It is raining. I *will take* an umbrella.

ភ្លៀងហើយ។ ចាំខ្ញុំយកឆ័ត្រ។

“Mr. Sinha is very busy at the moment.”—“All right. I'll wait.”

«លោក Sinha គាត់រវល់ណាស់ឥឡូវហ្នឹង។» «មិនអីទេ ចាំខ្ញុំចាំ។»

*GOING TO (= Future with intension = អនាគតកាលដែលបញ្ជាក់ពីបំណងប្រាថ្នា)*

238. We use the *going to* form (*be going to* + base of verb) when we have decided to do something before talking about it.

238. យើងប្រើទំរង់ going to (be going to + ទំរង់ដើមរបស់ Verb) នៅពេលយើងបានសំរេចចិត្តធ្វើអ្វីមួយមុននិយាយអំពីវា។

“Have you decided what to do?”—“Yes, I am going to resign the job.”

«តើអ្នកមានសំរេចចិត្តថាត្រូវធ្វើអ្វីហើយឬនៅ?» «សំរេចចិត្តរួចហើយ។ ខ្ញុំនឹងលាឈប់ពីការងារ។»

***ចង់បញ្ជាក់ថាមុនលាឈប់ពីការងារបានសំរេចចិត្តរួចហើយ។

to resign = លាលែងពីមុខតំណែង/ការងារ

“Why do you want to sell your motorbike?”—“I'm going to buy a car.”

«ហេតុអ្វីក៏អ្នកឯងចង់លក់ម៉ូតូ?» «ខ្ញុំនឹងទិញឡាន។»

***ប៉ងរួចហើយ។

to decide to do sth = សំរេចចិត្តថាធ្វើអ្វី១

to decide upon/on sth = ធ្វើការសំរេចចិត្តអំពីអ្វី១

to $\underbrace{decide}_{Vt}$ on sth

Sth is decided (up) on [Passive]

www.salarean.com

Remember that if the action is already decided upon and preparations have been made, we should see the *going to* form, not the Simple Future Tense. The Simple Future Tense is used for an instant decision.

ចូរចាំថាប្រសិនបើសកម្មភាពអ្វី១ត្រូវបានគេសំរេចចិត្តរួចទៅហើយ ហើយការរៀបចំត្រូវបានគេធ្វើរួចហើយ នោះយើងគួរតែប្រើទំរង់ going to មិនមែនប្រើ Simple Future Tense ទេ។ Simple Future Tense គឺគេប្រើសំរាប់ការសំរេចចិត្តភ្លាមៗ។

| *instant* / *immediate* | decision

239. We also use the *going to* form to talk about what seems likely or certain, when there is something in the present which tells us about the future.

239. យើងក៏ប្រើទំរង់ going to ដើម្បីនិយាយអំពីអ្វី១ដែលហាក់ដូចជាអាចកើតឡើង ឬ ហាក់ប្រាកដថានឹងកើតឡើងនៅពេលមានអ្វីនៅពេលបច្ចុប្បន្នដែលនិយាយប្រាប់យើងឲ្យដឹងពីពេលអនាគត។

seem likely = ហាក់ដូចជាអាច

likely (adj) = ទំនងជាអាច/ប្រហែលជាអាច

Sb is likely to do sth. Sb ទំនងជាអាចធ្វើអ្វី១

Sb ជា Subject របស់ is ផង, ជា Subject របស់ to-infinitive ផង។

***មានអ្វីនៅពេលបច្ចុប្បន្នដែលនិយាយប្រាប់យើងឲ្យដឹងពីហេតុការណ៍ថាអាចកើតឬក៏ប្រាកដជាកើតឡើងក្នុងពេលអនាគតហៅថាភស្តុតាង។ មានភស្តុតាងបង្ហាញថាហេតុការណ៍ហ្នឹងអាចកើតឡើងគឺគេប្រើ be going to ។ យើងមើលឃើញមេឃងងឹតទៅៗជាសញ្ញាមួយថានឹងមានភ្លៀងធ្លាក់ ត្រង់ហ្នឹងគេហៅថាភស្តុតាង។ កាលណាយើងមើលឃើញមានភស្តុតាងបង្ហាញថាអ្វី១ វាអាចកើតឡើងនៅក្នុងពេលអនាគត អញ្ចឹងអ្វីដែលនឹងកើតឡើងមិនប្រើ will ទេ គឺប្រើ going to ។

It *is going to* rain; look at those clouds.

វានឹងមានភ្លៀងធ្លាក់។ ន! មើលពពកខ្មៅ។

The boat is full of water. It *is going to* sink.

ទូកពេញទៅដោយទឹក/ទូកមានទឹកពេញ។ វានឹងលេចហើយ។

She *is going to* have a baby. គាត់នឹងមានកូន។

*** *Be going to*:

1. ប្រើសំរាប់បញ្ជាក់ពីបំណងប្រាថ្នាក្នុងពេលអនាគត ឬ ហៅថាការសំរេចចិត្តដែលបានធ្វើរួចហើយមុនពេលនិយាយអំពីការសំរេចចិត្តនោះ។
2. ប្រើសំរាប់អំពើដែលទំនងជាអាចកើតឡើងដោយសារតែមានភស្តុតាង នៅពេលបច្ចុប្បន្នថា ហេតុការណ៍ហ្នឹងអាចកើតឡើង។

www.salarean.com

240. The *going to* form may also express an action which *is on the point of* happening.

240. ទំរង់ going to នេះអាចបញ្ជាក់ពីសកម្មភាពមួយដែលរៀបនឹងកើតឡើង។

{ to be | on the point of / on the verge of | doing sth } = ហៀបធ្វើអ្វី១
to be about to do sth

Let's get into the train. It*'s going to leave*.

តស់យើងឡើងរថភ្លើង។ វាចេញឥឡូវហើយ។

Look! The craker is going to explode.

មើលន! ផាវហ្មឹងផ្ទុះឥឡូវហើយ។

*BE ABOUT TO*

241. *Be about to* + base form can also be used for the immediate future.

241. Be about to + ទំរង់ដើមរបស់ Verb ក៏អាចប្រើសំរាប់អនាគតកាលភ្លាមៗខាងមុខនេះដែរ។

Let's get into the train. It*'s about to leave*.

តស់យើងឡើងរថភ្លើង។ វាចេញឥឡូវហើយ។

Don't go out now. We *are about to have lunch*.

កុំចេញក្រៅឥឡូវណា។ យើងញាំបាយថ្ងៃត្រង់ឥឡូវហើយ។

Be going to មាន៣ចំណុច:

១. ប្រើសំរាប់បញ្ជាក់ពីបំណងប្រាថ្នាឬក៏ការសំរេចចិត្តដែលបានធ្វើរួចហើយ (បើការសំរេចចិត្តភ្លាមៗពេលនិយាយប្រើ will)

២. ប្រើសំរាប់បញ្ជាក់ពីអ្វីដែលមានលទ្ធភាពអាចកើតឡើងដោយសារតែមានភស្តុតាងបង្ហាញឲ្យឃើញថាវាអាចកើតឡើង។

He is going to have a cool.

៣. ប្រើសំរាប់អំពើដែលនឹងកើតភ្លាមៗនៅក្នុងពេលអនាគតខាងមុខនេះ។ (ដូចយើងថា: ឥឡូវហើយៗ)

be going to = be about

www.salarean.com

## *SIMPLE PRESENT TENSE*

(PRESENT TENSE ប្រើសំរាប់ FUTURE)

242. The Simple Present Tense is used for official programmes and timetables.

242. Simple Present Tense ប្រើសំរាប់កម្មវិធីឬកាលវិភាគផ្លូវការ។

(Present Simple ប្រើសំរាប់ Future)

(ច្រើននិយាយពីតារាងពេលវេលារបស់យន្តហោះ, រថភ្លើងចេញចូលឬក៏កម្មវិធីកិច្ចប្រជុំ)

The college *opens* on 23rd June.

មហាវិទ្យាល័យនឹងបើកនៅថ្ងៃទី២៣មិថុនា។

The film *starts* at 6.30 and *finishes* at 9.00.

រឿងកុនចាប់ផ្តើមលេងនៅម៉ោង៦.៣០ ហើយចប់នៅម៉ោង៩។

When *does* the next train *leave* for Chennai?

តើរថភ្លើងលើកក្រោយចាកចេញទៅ Chennai នៅម៉ោងប៉ុន្មាន?

(សួររកពេលចេញចូលគឺ timetable)

243. The Simple Present is often used for future time in clause with *if, unless, when, while, as (= while) before, after, until, by the time* and *as soon as*. The Simple Future Tense is not used in such cases.

243. Simple Present ជាញឹកញាប់ត្រូវគេប្រើសំរាប់ពេលអនាគតនៅក្នុង Clause ដែលប្រើជាមួយ if, unless, when, while, as (=while), before, after, until, by the time និង as soon as។ Simple Future Tense មិនត្រូវបានគេប្រើក្នុងករណីបែបនេះទេ។

unless = លុះណាតែ/បើមិន = if not

while = នៅពេលដែល

by the time = ត្រឹមពេលដែល

as soon as = នៅពេលដែល (បង្កប់ន័យ ភ្លាម)

I won't go out. It *will rain*.

↓

I won't go out *if* it *rains*.

Future Simple ប្តូរទៅជា Present Simple

Future Continuous ប្តូរទៅជា Present Contonuous

Future Perfect ប្តូរទៅជា Present Perfect

Can I have some milk before I go to bed?

ខ្ញុំផឹកទឹកដោះគោបានទេមុនពេលទៅដេក?

Can I have some milk? I *will go* to bed.

↓

Can I have some milk *before* I *go* to bed.

www.salarean.com

Please ring me up. He *will come*.

Please ring me up *as soon as* he *comes*.

Ring me up when you have finished dinner.

ចូរអ្នកទូរស័ព្ទមកខ្ញុំនៅពេលដែលអ្នកឯងញ៉ាំបាយល្ងាចរួច។

*Future Perfect*

Ring me up. You *will have finished* dinner.

Ring me up *when* you *have finished* dinner.

He *told* me toring him up *when* I *had finished* dinner.

*អំពើទី១* *អំពើទី២ Past Perfect*

I *arrived* when he *had left*.

*អំពើទី២* *អំពើទី១*

ខ្ញុំទៅដល់ពេលដែលគាត់ចេញបាត់ទៅហើយ។

Let's wait till he finished his work.

ចូរយើងរង់ចាំរហូតដល់គាត់ធ្វើកិច្ចការរបស់គាត់ហើយ។

Please ring me up *as soon as* he comes.

ចូរទូរស័ព្ទមកខ្ញុំភ្លាមនៅពេលដែលគាត់មកដល់។

www.salarean.com

## *PRESENT CONTINUOUS TENSE*

(Present Continuous ប្រើសំរាប់ Future)

244. We use the Present Continuous Tense when we talk about something that we have planned to do in the future.

244. យើងប្រើ Present Continuous Tense នៅពេលដែលយើងនិយាយអំពីអ្វីដែលយើងមានផែនការធ្វើនៅក្នុងពេលអនាគត។

I′m going to Shimla tomorrow. ស្អែកខ្ញុំទៅ Shimla។

We are eating out tonight. យប់ហ្នឹងយើងទៅញ៉ាំបាយនៅក្រៅហើយ។(ញ៉ាំបាយហាង)

Mr. Abdul Rehman is arriving this evening.

លោក Abdul Rehman នឹងមកដល់នៅល្ងាចនេះ។

You are advised to use the Present Continuous (not the Simple Present) for personal arrangements.

គេសុំធ្វើការណែនាំឲ្យអ្នកប្រើប្រាស់ Present Continuous (មិនមែន Simple Presentទេ) សំរាប់ការរៀបចំផ្ទាល់ខ្លួន។

*** Present Continuous ជាទូទៅប្រើសំរាប់ការរៀបចំផ្ទាល់ខ្លួន។ ផ្ទុយទៅវិញបើការរៀបចំហ្នឹងវាផ្លូវការ មានកម្មវិធី មានពេលវេលាត្រឹមត្រូវ ប្រើ Present Simple។ បើគ្រាន់តែប៉ងក្នុងចិត្តអត់មានធ្វើអ្វី ប្រើ be going to។

www.salarean.com

# *FUTURE CONTINUOUS TENSE*

***Future Continuous ប្រើសំរាប់អំពើមួយដែលនឹងកំពុងកើតឡើងត្រង់ចំណុចពេលវេលាមួយនៅពេលអនាគត។ ឧទាហរណ៍ថា ស្អែកម៉ោង៧អ្នកធ្វើអ្វី? ស្អែកម៉ោង៧ខ្ញុំកំពុងរៀន។ បានន័យថា ខ្ញុំនឹងកំពុងរៀន។ ពាក្យ«នឹងកំពុងរៀន» ធ្វើក្នុងពេលអនាគត។ បើសួរថា ម្សិលមិញពេលហ្នឹងអ្នកឯងកំពុងធ្វើអ្វី? កំពុងរៀនដែរ នេះជា «កំពុងរៀន» ក្នុងអតីតកាល។

245. We use the Future Continuous Tense to talk about actions which will be *in pregress* at a time in the future.

245. យើងប្រើ Future Continuous ដើម្បីនិយាយអំពីសកម្មភាពដែលនឹងកើតឡើងនៅត្រង់ពេលវេលាណាមួយក្នុងពេលអនាគត់។

in progress = កំពុងកើតឡើង

I suppose it *will be raining* when we start.

ខ្ញុំគិតថា ភ្លៀងនឹងកំពុងធ្លាក់ហើយនៅពេលចាប់ផ្តើមចេញដំណើរ។

This time tomorrow I *will be sitting* on the beach in Singapore.

ពេលថ្មល់ហ្នឹងថ្ងៃស្អែកខ្ញុំនឹងកំពុងអង្គុយលើឆ្នេរខ្សាច់នៅក្នុងប្រទេសសឹង្ហបុរីហើយ។

"Can I see you at 5 o'clock?"—"Please don't come then. I *will be watching* the tennis match on TV."

«តើខ្ញុំអាចជួបអ្នកនៅម៉ោង៥បានទេ?» «នៅពេលនោះកុំមកអីណា។ ខ្ញុំនឹងកំពុងមើលការប្រកួតកីឡា Tennis តាមទូរទស្សន៍។»

246. We also use this tense to talk about actions in the future which are already planned or which are expected to happen in the normal course of things.

246. យើងក៏ប្រើកាលនេះដើម្បីនិយាយអំពីអំពើនៅក្នុងពេលអនាគតដែលបានរៀបចំផែនការរួចហើយឬក៏ដែកគេរំពឹងថានឹងកើតឡើងតាមទំលាប់ធម្មតា។

course = របៀប, ផ្លូវ

in the course of = ក្នុងដំណើរនៃ

in the normal course of things = ក្នុងដំណើរធម្មតានៃអ្វី១

I *will be staying* here till Sunday.

ខ្ញុំនឹងស្នាក់នៅទីនេះរហូតដល់ថ្ងៃអាទិត្យ។

He *will be meeting* us next week.

គាត់នឹងជួបយើងនៅសប្តាហ៍ក្រោយ។

The postman *will be coming* soon.

អ្នករត់សំបុត្រនឹងមកដល់ក្នុងពេលឆាប់ៗ។

www.salarean.com

# BE TO

247. We use *be to* + base form to talk about official plans and arrangements.

247. យើងប្រើ be to បូកជាមួយនឹងទំរង់ដើមរបស់ Verb ដើម្បីនិយាយអំពីផែនការឬក៏ការរៀបចំជាផ្លូវការ។

***ការរៀបចំផ្ទាល់ខ្លួន(Personal Arragement) ប្រើ Present Continuous ។ តែបើឥតបានរៀបចំអ្វីទេ ហើយគ្រាន់តែប៉ងក្នុងចិត្ត ប្រើ be going to។ បើអត់ប៉ងហើយសំរេចចិត្តភ្លាមៗ ប្រើ will។

The Prime Minister is to visit America next month.

នាយករដ្ឋមន្ត្រីត្រូវទៅបំពេញទស្សនកិច្ច America នៅខែក្រោយ។

The conference is to discuss "Nuclear Tests."

សន្និសិទហ្នឹងត្រូវពិភាក្សាគ្នាអំពីការសាកល្បងអាវុធនុយក្លេអ៊ែរ។

*Be to* is used in a formal style, often in news reports. *Be* is usally left out in headlines, e.g. "Prime Minister to visit America".

Be to នេះត្រូវបានគេប្រើនៅក្នុងស្ទីលសរសេរជាផ្លូវការ ជាញឹកញាប់នៅក្នុងរបាយការណ៍ពត៌មាន។ Be to ជាទូទៅត្រូវគេលុបចោលនៅក្នុងចំណងជើងពត៌មាន ឧទាហរណ៍ "Prime Minister to visit America"។

***នៅក្នុងសារពត៌មាន be to ជាទូទៅត្រូវជំនួសដោយ will។

The PM *is to visit* America next month. (ឃ្លាធម្មតា)

The PM *will visit* America next month. (News report)

ក្នុងចំណងជើងការសែត (Headline)

1. Article: លុបចោល
2. | *be to* / *will* | + infinitive ជំនួសវិញដោយ "to-infinitive"
3. Be: អាចលុបចោល / Auxiliary: អាចលុបចោល
4. | *Past Simpe* / *Present Perfect* | ជំនួសវិញដោយ "Present Simple"

~~The~~ PM | *~~is~~ to visit* / *~~will~~ to visit* | America next month. (Headline)

=> PM to visit Amerca next month

~~The~~ PM *~~will~~* (*to*) visit America next month.

=> PM to visit America next month

~~A~~ terrorist ~~was~~ arrested in ~~a~~ dawn raid.

=> Terrorist arrested in dawn raid. (= A terrorist was arrested……)

***ក្នុងចំណងជើងកាសែត to-infinitive មានន័យថា Future។

www.salarean.com

~~A~~ meeting *was* held at the national stadium.

*is ជំនួស*

[Present Simple ប្រើសំរាប់ជំនួស Past Simple ឬ Present Perfect]

*** Future ដែលនឹងកើតឡើងភ្លាមៗដូចថា ខ្ញុំទៅឥឡូវហើយឬថារថភ្លើងចេញឥឡូវហើយ ប្រើ to be about to do sth ឬ to be on the verge of doing sth ឬ to be on the point of doing sth។

*** ប៉ុន្តែចំពោះ Verb: go និង come គេប្រើកាល Continuous តែម្តង។

ឧទាហរណ៍: កណ្តឹងរ៉ោចេញពីថ្នាក់រៀន ហើយអ្នកនៅរេរ៉ ហើយខ្ញុំសួរថា អ្នកឯងមិនទាន់ទៅទេ? អ្នកឆ្លើយថា ខ្ញុំទៅឥឡូវហើយ។ ទៅឥឡូវហើយ ន័យដូចប្រើ be about តែគេមិនប្រើ be about ទេ គឺគេប្រើ Present continuous តែម្តង: I'm going (ខ្ញុំនឹងទៅ)។

ឧទាហរណ៍ថា: ពេលកណ្តឹងចូលរៀនមិនឃើញមិត្តភក្តិចូលអង្គុយរៀននៅឡើយ ហើយមានគេសួរថា ឯណាមិត្តអ្នកឯង។ អ្នកឆ្លើយថា គាត់មកឥឡូវហើយ គឺ He/ she is coming។ មិនបាច់ដាក់ Adverb ទេ។

www.salarean.com

## *FUTURE PERFECT TENSE*

*** Present Perfect ប្រើសំរាប់អំពើដែលកើតឡើងក្នុងអតីតកាល (កើតពីពេលណាគេមិននិយាយ កន្លែងដែលគេនិយាយគឺ កន្លែងដែលវាមកដល់ ហើយចំណុចដែលវាមកដល់គឺ Momment of Speaking វាអាចដល់ចប់ត្រឹមហ្នឹង ឬ មកដល់ត្រឹមហ្នឹង។




បើយើងរំកិល Moment of Speaking ទៅដូច្នេះវិញ (រូបខាងក្រោម)




ចំណុចសំខាន់គឺ Moment of Speaking ក្លាយទៅជាចំណុចពេលវេលាមួយដែលកន្លងមកដល់ត្រង់ចំណុចហ្នឹងអំពើមុខមកទៀតកើតមកដល់។

ដូច្នេះ បើប្តូរ Moment of Speaking (ដូចរូបក្រោម) ទៅជា Future Perfect។




ដូច្នេះ Present Perfect អំពើកើតឡើងពីក្នុងអតីតកាលបន្តមកដល់ឬបញ្ចប់ត្រឹម Moment of Speaking។

Past Perfect អំពើដែលកើតមកដល់ឬមកចប់ត្រង់ចំណុចពេលវេលាច្បាស់លាស់មួយក្នុងអតីតកាលគឺត្រឹមកន្លែងដែលធ្លាប់ជា Moment of Speaking របស់ Present Perfect។

Future Perfect អំពើដែលនឹងទៅចប់ឬទៅដល់ត្រង់ចំណុចពេលវេលាជាក់លាក់មួយនៅពេលអនាគត។

248. The Future Tense is used to talk abouts that will be completed by a certain future time.

248. The Future Perfect Tense គឺប្រើដើម្បីនិយាយអំពីសកម្មភាពដែលនឹងចប់ត្រង់/ត្រឹមចំណុចពេលវេលាជាក់លាក់មួយក្នុងពេលអនាគត។

***ចំណុចសំខាន់របស់ Future Perfect គេរកមើលចំណុចពេលវេលាដែលអំពើនឹងទៅដល់ រីឯចំណុចសំខាន់របស់ Past Perfect គេរកមើលចំណុចពេលវេលាដែលអំពើមកដល់ ចំណែក Present Perfect គឺ Moment of Speaking ជាចំណុចពេលវេលា គឺពេលនិយាយ។

I *shall have written* my exercise by then.

ខ្ញុំនឹងសរសេរលំហាត់រួចហើយគិតទៅដល់ត្រឹមពេលនោះ។

by then = ទៅដល់ត្រឹមពេលនោះ / គិតទៅដល់ត្រឹមពេលនោះ

He *will have left* before you go to see him.

គាត់នឹងចេញបាត់ទៅហើយមុនពេលដែលអ្នកទៅលេងគាត់។

www.salarean.com

*** ចំណុចពេលវេលាគឺពេលអ្នកឯងទៅលេងគាត់ (ហើយបើទៅជួបគាត់ថ្ងៃសៅរ៍ គឺថ្ងៃសៅរ៍ ជាចំណុចពេលវេលា) ហើយមកដល់ត្រង់ចំណុចហ្នឹង អំពើមួយកើតរួចបាត់ទៅហើយ។

បើយើងលើកវាទៅអតីតកាលវិញ ប្រើកាល Past Perfect + Past Simple (មុនពេលខ្ញុំទៅលេងគាត់ គាត់ចេញបាត់ទៅហើយ។) ដោយ Past Perfect ទៅ Future Perfect។ ហើយឃ្លា before you go មិនដាក់ថា before you will go...... ពីព្រោះ Present Simple ប្តូរមកពី Future Simple ដោយសារពាក្យ before។

By the end of this month = គិតទៅដល់ត្រឹមដំណាច់ខែនេះ

By the end of this month I will have worked here for five years.

គិតទៅដល់ដំណាច់ខែនេះ ខ្ញុំបានធ្វើការនៅទីនេះអស់រយៈពេល៥ឆ្នាំហើយ។

(៥ឆ្នាំហ្នឹង គិតពីពេលណាមក គេអត់ដឹងទេ គេគ្រាន់តែដឹងថា ដល់ដំណាច់ខែហ្នឹង គឺ ៥ឆ្នាំ។)




*** Past Perfect, Present Perfect និង Future Perfect គេមិននិយាយពីចំណុចចាប់ផ្តើមទេ ទោះបីជាវាចាប់ផ្តើមពីចំណុចណាក៏ដោយ គេនិយាយតែវាទៅដល់កន្លែងណា។

www.salarean.com

# FUTURE PERECT CONTINUOUS TENSE

249. The Future Perfect Continous tense is used for actions which will be in progress over a period of time that will end in the future.

249. Future Perfect Continuous គឺត្រូវបានគេប្រើសំរាប់សកម្មភាពដែលនឹងកំពុងកើតឡើង មួយរយៈពេលដែលនឹងចប់ក្នុងពេលអនាគត។

in progress = កំពុងកើតឡើង / កំពុងប្រព្រឹត្តទៅ

over a period of time = មួយរយៈពេល

By next March we *shall have been having* here for four years.

គិតទៅដល់ត្រឹមខែមីនាក្រោយយើង | នឹងរស់នៅ<br>នឹងបានកំពុងរស់នៅ | ទីនេះបានអស់រយៈពេល៤ឆ្នាំហើយ។

I'*ll have been teaching* for twenty years next July.

គិតទៅដល់ត្រឹមខែ July ក្រោយ ខ្ញុំនឹងបានបង្រៀនអស់ពេល២០ឆ្នាំហើយ។

This tense is not very common.

កាលនេះមិនប្រើទូទៅទេ។

*** ចង់សង្កត់ធ្ងន់ទៅលើពេលវេលា ប្រើទំរង់ -ing form

(Duration) ឧ. គិតទៅដល់ពេលហ្នឹង២០ឆ្នាំហើយគឺមិនធម្មតាទេ។

*** ចង់សង្កត់លើអំពើ ប្រើ PerfectSimple

ឧ. គិតទៅដល់ពេលហ្នឹងនៅបង្រៀននៅឡើយ អត់ឈប់ទេ។

www.salarean.com